**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធម្មការនិងសាសនា**
លេខ: ១១/២៤ ក.ធ.ស.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំពិធីបុណ្យវិសាខបូជា

**បុណ្យវិសាខបូជា** ជាបុណ្យមួយដ៏សំខាន់បំផុត ដែលប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទទូទាំងពិភពលោក ក៏ដូចជាកម្ពុជា តែងប្រារព្ធធ្វើជារៀងរាល់ឆ្នាំ ដើម្បីរម្លឹកនឹកដល់អភិលក្ខិតសម័យទាំងបី គឺថ្ងៃដែលព្រះពុទ្ធទ្រង់ប្រសូតិ ត្រាស់ដឹង និងបរិនិព្វាន នាថ្ងៃ ១៥កើត ពេញបូណ៌មី ក្នុងខែពិសាខដូចគ្នា។ទន្ទឹមនឹងនេះ **បុណ្យវិសាខបូជា** ត្រូវបានអង្គការសហប្រជាជាតិប្រកាសទទួលស្គាល់នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៩ ហើយបានប្រារព្ធធ្វើនៅការិយាល័យអង្គការសហប្រជាជាតិ ជារៀងរាល់ឆ្នាំ។

ឆ្នាំនេះ ពិធី **បុណ្យវិសាខបូជា** រាជរដ្ឋាភិបាល បានរៀបចំជាផ្លូវការ នៅថ្ងៃពុធ ១៥កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ និងថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០២៤ ក្នុងបរិវេណ **ព្រះមហាសក្យមុនីចេតិយ ភ្នំព្រះរាជទ្រព្យ (ឧដុង្គ)** ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាតិ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ព្រះសង្ឃ និងពុទ្ធបរិស័ទយ៉ាងច្រើនអធិកអធម។ ដោយឡែកនៅតាមបណ្តាវត្តអារាមទូទាំងប្រទេស បានរៀបចំពិធីបុណ្យនេះព្រមៗគ្នាដែរ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា **ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។**

ដើម្បីឱ្យពិធី**បុណ្យវិសាខបូជា** ឆ្នាំនេះ មានភាពឱឡារិកអធិកអធម ក្រសួងធម្មការនិងសាសនា សូមធ្វើការណែនាំដល់មន្ទីរធម្មការនិងសាសនា គ្រប់រាជធានី ខេត្ត ដូចខាងក្រោម៖

១-ត្រូវសហការជាមួយសាលាគណ និងរដ្ឋបាលរាជធានី ខេត្ត ដើម្បីធ្វើការផ្សព្វផ្សាយពីខ្លឹមសារស្តីពី **បុណ្យវិសាខបូជា** ដល់ប្រជាពុទ្ធបរិស័ទ និងយុវជនគ្រប់មជ្ឈដ្ឋានឱ្យបានយល់ជ្រួតជ្រាបអំពីអត្ថន័យនៃពិធី**បុណ្យវិសាខបូជា**។

២-ត្រូវបំផុសឱ្យគ្រប់វត្តអារាម រៀបចំពិធីបុណ្យវិសាខបូជាឱ្យបានមហោឡារិក ស្របតាមទំនៀមទម្លាប់ ប្រពៃណីជាតិ និងព្រះពុទ្ធសាសនា។ សម្រាប់នៅតាមបណ្តារាជធានី ខេត្ត នីមួយៗ ត្រូវជ្រើសរើសវត្តណាមួយដែលមានលក្ខណៈសមស្រប ប្រារព្ធពិធី **បុណ្យវិសាខបូជា** ជាផ្លូវការ។

៣-ត្រូវសហការជាមួយព្រះមេគណ ព្រះអនុគណ ណែនាំដល់ព្រះគ្រូចៅអធិការ អាចារ្យ គណៈកម្មការគ្រប់វត្ត មណ្ឌលវិបស្សនាធុរៈ និងអាស្រមព្រះពុទ្ធសាសនាធ្វើការបោសសម្អាតទីធ្លា ព្រះវិហារ កុដិ ឧបដ្ឋានសាលា និងកន្លែងគោរពសក្ការៈបូជា ព្រមទាំងតុបតែងលម្អផ្កាភ្ញី បំភ្លឺភ្លើង ចងបដា ដែលមានរូបភាពព្រះពុទ្ធទ្រង់ប្រសូតិ ត្រាស់ដឹង បរិនិព្វាន និងចងទង់ជាតិ ទង់សាសនា ទង់ព្រះមហាក្សត្រ ព្រមទាំងបដាពាក្យស្លោកផ្សេងៗ ត្រូវរៀបចំឱ្យមានពិធីចម្រើនព្រះបរិត្ត សម្តែងព្រះធម៌ទេសនា និងដឹកនាំពុទ្ធបរិស័ទសូត្រធម៌បទ ធ្វើសមាធិកម្មដ្ឋាន ជាដើម។



អាសយដ្ឋាន៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ (៨៥៥-២៣) ៧២២ ៦៥៥
អ៊ីម៉ែល៖ mocargovkh@gmail.com
គេហទំព័រ៖ www.mocar.gov.kh

៤-គ្រប់វត្តអារាម មណ្ឌលវិបស្សនា អាស្រមព្រះពុទ្ធសាសនា ត្រូវរៀបចំតាំងព្រះឆាយាលក្ខណ៍ **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី កិត្តិឧទ្ទេសបណ្ឌិត នេត ខេង** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រារព្ធពិធីបង្សុកូលឧទ្ទិសព្រះរាជមហាកុសល ថ្វាយព្រះវិញ្ញាណក្ខន្ធព្រះបរមសព។

៥-សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ការពារសុវត្ថិភាពក្នុងពិធីបុណ្យ និងបំផុសសប្បុរសជន ពុទ្ធបរិស័ទ ប្រជាពលរដ្ឋ ឱ្យអញ្ជើញចូលរួមបំពេញកុសលតាមសទ្ធាជ្រះថ្លា ក្សោឱ្យបាននូវប្រពៃណីដ៏ល្អផូរផង់របស់ព្រះពុទ្ធសាសនា និងអនុមោទនាយកអានិសង្សរៀងៗខ្លួន។

ទទួលបានសេចក្តីណែនាំនេះ លោកប្រធានមន្ទីរធម្មការនិងសាសនា រាជធានី ខេត្ត ត្រូវសហការជាមួយព្រះមេគណ ព្រះអនុគណ គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រះគ្រូចៅអធិការគ្រប់វត្ត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។ន

ថ្ងៃចន្ទ ១៤ កើត ខែ ចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០២៤
រដ្ឋមន្ត្រី ម

ចាយ_បុរិន

**ចម្លងថ្វាយ-ប្រគេន-ជូន**

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- សម្តេចព្រះសង្ឃនាយកទាំងពីរគណៈ
- ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

"ដើម្បីថ្វាយ-ប្រគេន-ជូនជ្រាប"

- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរធម្មការនិងសាសនា រាជធានី ខេត្ត
- សាលាគណរាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ